**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៩៦៥ ព.ណ ករប

ភ្នំពេញ, ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

កន្លងមក ក្រសួងពាណិជ្ជកម្ម បានសង្កេតឃើញថា មានសហគ្រាស និងក្រុមហ៊ុនមួយចំនួន បានយកឈ្មោះ និងនិមិត្តសញ្ញាអង្គការអន្តរជាតិ មកប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ដែលការប្រើប្រាស់បែបនេះ ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិម្ចាស់សិទ្ធិ និងត្រូវបានចាត់ទុកជាការរំលោភច្បាប់ ។

ទន្ទឹមនឹងនេះដែរ ឈ្មោះ **"អូឡាំពិក"** និង **"និមិត្តសញ្ញាកងប្រាំអូឡាំពិក"** របស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ និងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក៏ត្រូវបានគេយកមកប្រើប្រាស់ ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងកេងចំណេញផលប្រយោជន៍ពាណិជ្ជកម្មរបស់ខ្លួន។ ហេតុដូចនេះ ក្រសួងពាណិជ្ជកម្មសូមជម្រាបជូន សាធារណជន អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាអគ្គនាយក អគ្គនាយិកា នៃសហគ្រាសនិងក្រុមហ៊ុនទាំងអស់ មេត្តាជ្រាបថា ទង្វើបែបនេះត្រូវបានចាត់ទុកជាការរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាក ដែលបានការពារនៅក្នុង៖

១- មាត្រា៦ស្ទួន ៣ (ខ) នៃអនុសញ្ញាទីក្រុងប៉ារីស ដែលចែងថា ការចុះបញ្ជី ឬការប្រើប្រាស់ឬការត្រាប់តាម ឈ្មោះ ឬនិមិត្តសញ្ញា របស់អង្គការអន្តររដ្ឋាភិបាល ដែលក្នុងនោះមានប្រទេសមួយឬច្រើនរបស់អនុសញ្ញានេះ ជាសមាជិក ត្រូវបានបដិសេធ ឬហាមឃាត់ លុះត្រាតែមានការអនុញ្ញាតពីស្ថាប័នទាំងនោះ។

២- មាត្រា៤ (ឃ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលចែងអំពីកិច្ចការពារឈ្មោះ ឬនិមិត្តសញ្ញាបែបនេះ។

ម្ចាស់ដើមនៃម៉ាក មានសិទ្ធិប្តឹងទៅតុលាការ ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ច ប្រឆាំងនឹងបុគ្គលណាមួយ ដែលប្រើប្រាស់ ឬត្រាប់តាម ដោយរំលោភបំពាន នូវម៉ាករបស់ខ្លួន ដោយគ្មានការអនុញ្ញាត។ ជនល្មើស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារ ឬទោសណាមួយនៃទោសទាំងពីរនេះ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មសូមជូនដំណឹងដល់សាធារណជន អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាអគ្គនាយក អគ្គនាយិកា នៃសហគ្រាស និងក្រុមហ៊ុនទាំងអស់ ត្រូវបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពប្រើប្រាស់រូបសញ្ញា ឬ និមិត្តសញ្ញា ដែលនាំឲ្យមានការភាន់ច្រឡំទៅនឹងឈ្មោះ **"អូឡាំពិក"** និង **"និមិត្តសញ្ញាកងប្រាំអូឡាំពិក"** និងនិមិត្តសញ្ញាអង្គការអន្តរជាតិនានាដទៃទៀត ដែលត្រូវបានការពារ។

ក្រសួងពាណិជ្ជកម្ម សង្ឃឹមយ៉ាងមុតមាំថា សាធារណជន អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាអគ្គនាយក អគ្គនាយិកា នៃសហគ្រាស និងក្រុមហ៊ុនទាំងអស់ នឹងសហការជាមួយក្រសួង ក្នុងការទប់ស្កាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា និងចូលរួមអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឲ្យមានប្រសិទ្ធភាព។

**ក្រសួងពាណិជ្ជកម្ម**

ឡូតិ៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ/ ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*